*សេចក្តីប្រកាសព័ត៌មាន*

# នាទិវាពិភពលោកប្រឆាំងពលកម្មកុមារ យូនីសេហ្វអំពាវនាវឱ្យបង្កើនកិច្ចការពារកុមារដែលកំពុងផ្លាស់ទី

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥ - នាទិវាពិភពលោកប្រឆាំងពលកម្មកុមារ យូនីសេហ្វអំពាវនាវឱ្យមានសកម្មភាពបន្ថែមទៀត ដើម្បីការពារសិទ្ធិកុមារដែលរងផលប៉ះពាល់ពីទេសន្តរប្រវេសន៍។ របាយការណ៍ស្រាវជ្រាវស្តីពីស្ថានភាពកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ រវាងប្រទេសកម្ពុជា និងប្រទេសថៃ[1] នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការគាំទ្រពីយូនីសេហ្វ ជាមួយនឹងការផ្តល់មូលនិធិពីសហភាពអឺរ៉ុប (EU) តាមរយៈកម្មវិធី PROTECT បង្ហាញអំពីវិសាលភាពនៃហានិភ័យពាក់ព័ន្ធនឹងកិច្ចការពារកុមារ ដែលធ្វើទេសន្តរប្រវេសន៍នៅក្នុងប្រទេសកម្ពុជា និងទៅកាន់ប្រទេសជិតខាង។ ហានិភ័យទាំងនេះ រួមមាន អំពើជួញដូរមនុស្ស ការរំលោភបំពាន ការកេងប្រវ័ញ្ច ភាពមានទំនាស់នឹងច្បាប់ និងពលកម្មកុមារ។

“ពលកម្មកុមារ ធ្វើឱ្យកុមារបាត់បង់សិទ្ធិក្នុងការទទួលបានកុមារភាពប្រកបដោយសុវត្ថិភាព និងសុខភាពរឹងមាំ មិនបានទទួលការអប់រំ ព្រមទាំងបំផ្លាញសុខុមាលភាពផ្លូវកាយ និងផ្លូវចិត្តរបស់កុមារ” នេះជាប្រសាន៍របស់លោកបណ្ឌិត វៀល ផាកស៍ នាយកយូនីសេហ្វប្រចាំកម្ពុជា។ “ទោះជាពួកគេធ្វើទេសន្តរប្រវេសន៍តែម្នាក់ឯង ឬជាមួយគ្រួសារនៅក្នុងប្រទេស ឬឆ្លងកាត់ព្រំដែនក្តី កុមារគឺងាយរងគ្រោះពីហានិភ័យទាំងនេះ។ ដោយគ្មានឯកសារស្របច្បាប់ កិច្ចការពារ និងលទ្ធភាពទទួលបានការអប់រំ កុមារទេសន្តរប្រវេសន៍ប្រឈមនឹងហានិភ័យកាន់តែខ្ពស់ពីការកេងប្រវ័ញ្ចនានា។”

លោកបណ្ឌិត វៀល ផាកស៍ បានបន្តទៀតថា “ដោយសហការជាមួយសហភាពអឺរ៉ុប យូនីសេហ្វកំពុងធ្វើការងារយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរ និងអ្នកពាក់ព័ន្ធ ដើម្បីពង្រឹងប្រព័ន្ធកិច្ចការពារកុមារឆ្លងដែនរវាងប្រទេសកម្ពុជា និងប្រទេសជិតខាង ជាពិសេស ធានាការទទួលបានសេវាចាំបាច់ និងអនុវត្តវិធានការដោយឥតរុញរា ដើម្បីធ្វើឱ្យកុមារទេសន្តរប្រវេសន៍មានសុវត្ថិភាព និងទទួលបានការគាំទ្រ។”

នៅឆ្នាំ ២០២៤ នៅទូទាំងសកលលោក កុមារចំនួនជិត ១៣៨ លាននាក់ បានរងនូវពលកម្មកុមារ រួមទាំងកុមារប្រមាណ ៥៤លាននាក់ កំពុងធ្វើការងារប្រកបដោយគ្រោះថ្នាក់ ដែលអាចបង្កគ្រោះថ្នាក់ចំពោះសុខភាព សុវត្ថិភាព ឬការអភិវឌ្ឍរបស់ពួកគេ នេះបើយោងតាមការប៉ាន់ស្មានថ្មី ដែលអង្គការអន្តរជាតិខាងការងារ (ILO) និងយូនីសេហ្វបញ្ចេញនៅថ្ងៃនេះ[2]។ ទិន្នន័យចុងក្រោយគេបង្ហាញនូវការធ្លាក់ចុះចំនួនកុមារសរុបជាង ២០លាននាក់ ចាប់តាំងពីឆ្នាំ ២០២០ មក ដែលនេះជាការបង្ហាញភាពធូរស្រាលឡើងវិញពីការកើនឡើងគួរឱ្យព្រួយបារម្ភនៅចន្លោះឆ្នាំ២០១៦ និងឆ្នាំ២០២០។

ក្នុងរយៈពេលមួយទសវត្សរ៍មុន ប្រទេសកម្ពុជាបានចាត់វិធានការចម្បងៗ ដើម្បីការពារកុមារពីអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពាន។ នៅរវាងឆ្នាំ ២០១០ និងឆ្នាំ ២០២១ សមាមាត្រនៃកុមារដែលចូលរួមនៅក្នុងពលកម្មកុមារ បានធ្លាក់ចុះពី ៣៧ភាគរយ មកនៅត្រឹម ១៧ភាគរយ។ ថ្វីបើមានវឌ្ឍនភាពបែបនេះក្តី ចំនួននេះនៅតែគួរឲ្យព្រួយបារម្ភ ដោយកុមារម្នាក់ក្នុងចំណោមកុមារ ៥នាក់ នៅកម្ពុជា កំពុងចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច[3]។ របាយការណ៍ស្រាវជ្រាវស្តីពី ស្ថានភាពកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ រវាងប្រទេសកម្ពុជា និងប្រទេសថៃ បង្ហាញថា ភាពក្រីក្រជារឿយៗបានជំរុញឲ្យកុមារធ្វើចំណាកស្រុកពីកម្ពុជាទៅប្រទេសថៃ ហើយពួកគេប្រឈមមុខនឹងហានិភ័យកាន់តែខ្ពស់ពាក់ព័ន្ធនឹងពលកម្មកុមារ ជាពិសេស នៅពេលដែលពួកគេបែកចេញពីគ្រួសាររបស់ពួកគេ។[4] កុមារដែលឆ្លងដែនដោយខុសច្បាប់ប្រឈមនឹងហានិភ័យឥតឈប់ឈរពីអំពើជួញដូរមនុស្ស ការរំលោភបំពាន ការកេងប្រវ័ញ្ច និងបំពានច្បាប់។ កុមារជា

---

[1 4 5] របាយការណ៍ស្រាវជ្រាវស្តីពី ស្ថានភាពកុមារដែលរងផលប៉ះពាល់ដោយទេសន្តរប្រវេសន៍ រវាងប្រទេសកម្ពុជា និងប្រទេសថៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខែមករា ឆ្នាំ២០២៥

[2] Despite progress, child labour still affects 138 million children globally – ILO, UNICEF

[3] Cambodia Demographic and Health Survey (CDHS), 2021–22.

ច្រើនពុំបានទៅរៀន ដោយសារគ្រួសាររបស់ពួកគេពឹងផ្អែកលើប្រាក់ចំណូលប្រចាំថ្ងៃ និងពុំមានលទ្ធភាពទទួលបានសេវាចាំបាច់នានា ដូចជា ការថែទាំសុខភាពជាដើម។

ពលកម្មកុមារក៏ជះឥទ្ធិពលលើកុមារដែលស្ថិតនៅក្នុងប្រទេសកម្ពុជាផងដែរ។ ពួកគេធ្វើការងារនៅតាមទីកន្លែងផ្សេងៗគ្នា រួមទាំងនៅការដ្ឋានសំណង់ និងភោជនីយដ្ឋាន និង កុមារអាយុអប្បបរមាការងារចូលរួមនៅក្នុងស្ថានភាពពលកម្មកុមារពាក់ព័ន្ធនឹងការលក់ដូរ ការងារតាមផ្ទះ ការកាត់ដេរសម្លៀកបំពាក់ កសិកម្ម ការកែច្នៃអាហារសមុទ្រ ការនេសាទ និងការសុំទានដោយមានការរៀបចំ[5]។ កុមារមានពិការភាពស្ថិតក្នុងចំណោមកុមារងាយរងគ្រោះបំផុត ដោយសារពួកគេអាចត្រូវបានគេប្រើប្រាស់ដើម្បីយកទៅសុំទាន ហើយពួកគេពុំមានលទ្ធភាពគ្រប់គ្រាន់ដើម្បីទទួលបានសេវាចាំបាច់ឡើយ។

ហានិភ័យអាកាសធាតុ ដូចជា ភាពរាំងស្ងួត ទឹកជំនន់ និងកម្ដៅក្ដៅហួសប្រមាណ បានរំខានជីវភាពរស់នៅ និងបង្ខំគ្រួសារជាច្រើន ជាពិសេស គ្រួសារជនទេសន្តរប្រវេសន៍ ឱ្យជួបការលំបាក និងបំពេញការងារប្រកបដោយគ្រោះថ្នាក់។ ហានិភ័យអាកាសធាតុទាំងនេះ មានទំនាក់ទំនងកាន់តែច្រើនឡើងជាមួយពលកម្មកុមារ ដែលនាំឲ្យប៉ះពាល់ដល់ប្រាក់ចំណូលរបស់គ្រួសារ និងរុញច្រានឱ្យកុមារធ្លាក់ក្នុងការកេងប្រវ័ញ្ចការងារ។ នេះគឺជាបញ្ហាប្រឈមដោយផ្ទាល់ចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ទី ៨ ដែលអំពាវនាវឱ្យមានការលុបបំបាត់ពលកម្មកុមារ និងកិច្ចការពារពលករងាយរងគ្រោះ។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ យូនីសេហ្វអំពាវនាវឱ្យមានការពង្រឹងកិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែន ដើម្បីបង្កើតប្រព័ន្ធការពារកុមាររួមគ្នាប្រកបដោយភាពរឹងមាំ ដែលធានាសុវត្ថិភាព និងសុខុមាលភាពរបស់កុមារងាយរងគ្រោះ។

###

អំពីយូនីសេហ្វ

យូនីសេហ្វធ្វើការងារនៅតាមទីកន្លែងលំបាកបំផុតមួយចំនួននៅក្នុងពិភពលោក ដើម្បីគាំទ្រដល់កុមារដែលស្ថិតក្នុងស្ថានភាពលំបាកបំផុត។នៅក្នុងប្រទេស និងដែនដីចំនួនជាង ១៩០ យើងធ្វើការងារដើម្បីកុមារគ្រប់រូបនៅគ្រប់ទីកន្លែង ដើម្បីកសាងពិភពលោកមួយកាន់តែល្អសម្រាប់មនុស្សគ្រប់រូប។ សម្រាប់ព័ត៌មានបន្ថែមអំពី យូនីសេហ្វ និងការងារនៅកម្ពុជា សូមចូលទៅកាន់៖ www.unicef.org.kh

សូមតាមដានយូនីសេហ្វប្រចាំកម្ពុជានៅលើ Facebook | Twitter | YouTube | Instagram | LinkedIn | Threads | TikTok

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

លោក Hadrien Bonnaud
ប្រធានផ្នែកទំនាក់ទំនង យូនីសេហ្វប្រចាំកម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣ ២៦០ ២០៤ អ៊ីម៉េល៖ hbonnaud@unicef.org

លោក ចាន់ ទី
អ្នកឯកទេសផ្នែកទំនាក់ទំនង យូនីសេហ្វប្រចាំកម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣ ២៦០ ២០៤ អ៊ីម៉េល៖ tchan@unicef.org